ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
*Nation - Religion - King*

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*

លេខ ១៦៧២ ព.ណ.ភ.ស.ប

ភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន តាំង សេង ហួត អ៊ិនធើណាសិនណាល**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលត្រីខកំប៉ុងម៉ាក SEACROWN® ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណាសិនណាល** ។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណាសិនណាល** ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៥
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Pataya Food Industries Limited ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៥
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២០៧៩៩/០៤ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលត្រីខកំប៉ុងពាក់ម៉ាកខាងលើ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តាំង សេង ហួត អ៊ិនធើណាសិនណាល** ដែលទទួលបានពីក្រុមហ៊ុន Pataya Food Industries Limited ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានេះ មានសុពលភាពត្រឹមថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៧ ដោយគិតចាប់ពីក្រោយថ្ងៃចុះហត្ថលេខាចំនួន៩០ (កៅសិប) ថ្ងៃ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Pataya Food Industries Limited ដែលជាម្ចាស់ម៉ាក ។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះ ក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តិ ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**ចម្លងជូន:**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ